# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ០០២៣/១៥ ក.អ.ជ

ថ្ងៃអង្គារ ១៤ កើត ខែផល្គុន ឆ្នាំមមី ព.ស.២៥៥៨

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា គ.ស ២០១៥

## សេចក្តីណែនាំ

<u>យោង</u> ÷
- លិខិតលេខ ៦៩៥៦ សហវ.អ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លិខិតលេខ ៧៩៣/១៤ ទរពអ.រប លេខ ៨១៥/១៤ ទរពអ.រប និងលេខ ៨២៩/១៤ ទរពអ.រប ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- លិខិតលេខ ៨៨២/១៤ ទរពអ.រប និងលេខ ៨៩៤/១៤ ទរពអ.រប ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០១៤ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- របាយការណ៍ប្រជុំលេខ ០២៩-១០/១៤ កអជ/ហរ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១៤
- របាយការណ៍ប្រជុំលេខ ០០២-១/១៤ កអជ/ហរ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១៥

សូមជម្រាបជូន **លោក លោកស្រី** ជាប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ២៥ រាជធានី-ខេត្ត ជ្រាបថា ក្រោយពីមានកិច្ចប្រជុំស្រាយបំភ្លឺទៅនឹងលិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលិខិតរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រួចមក និងដើម្បីប្រសិទ្ធភាពការងារសម្រាប់ឆ្នាំ ២០១៥ នេះ ក្រសួងសូមធ្វើការណែនាំដល់លោក លោកស្រី ជាប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពតាមសេចក្តីណែនាំដូចខាងក្រោម ÷

- ចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ រួមមាន ប្លង់ដី អគារ អចលនៈទ្រព្យផ្សេងៗ របស់មន្ទីរឱ្យច្បាស់លាស់ និងឆាប់រហ័សបំផុត
- សមិទ្ធផលដែលបានសាងសង់រួចដូចជា ផ្លូវ ស្ពាន ទំនប់បង្ហៀរទឹក បង្គន់អនាម័យ អណ្តូងទឹក ស្រះទឹក អាងទឹក ត្រូវដាក់ស្លាកសញ្ញាសម្គាល់របស់ក្រសួងអភិវឌ្ឍន៍ជនបទ ឱ្យបានត្រឹមត្រូវតាមបណ្តាឆ្នាំនីមួយៗ
- ត្រូវបង់លេខសម្គាល់លើសម្ភារៈសង្ហារឹមឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ
- មន្ទីរត្រូវយកចិត្តទុកដាក់ពិនិត្យមើល រថយន្ត ម៉ូតូ សម្ភារៈប្រើប្រាស់ផ្សេងៗ ដែលចាស់ទ្រុឌទ្រោមប្រើលែងកើត ត្រូវសុំគោលការណ៍ជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

- ត្រូវពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងបន្ថែមទៀតដូចជា វត្តមាន និងអវត្តមាន របស់មន្ទីរដើម្បីប្រសិទ្ធភាពក្នុងការអនុវត្តការងារ ពិសេសនីតិវិធីនៃការគ្រប់គ្រងរដ្ឋបាល ស្របទៅតាមច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- ក្នុងករណីអធិការកិច្ចឱ្យធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីនីតិវិធីកែលម្អ គ្រប់ប្រធានមន្ទីរត្រូវរៀបចំធ្វើរបាយកាណ៍ឆ្លើយតបទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យបានទាន់ពេលវេលា រួចចម្លងជូនអគ្គាធិការដ្ឋាន និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងអភិវឌ្ឍន៍ជនបទ
- ត្រូវមានទំនាក់ទំនង និង ផ្លាស់ប្តូរព័ត៌មានជាមួយអគ្គាធិការដ្ឋាន នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ និងនាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួង នៅពេលមានចម្ងល់ ឬបញ្ហាពាក់ព័ន្ធទៅលើលិខិតបទដ្ឋានគតិយុត្ត លិខិតយុត្តិការ និងនីតិវិធីហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះ សូម **លោក លោកស្រី** ជាប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ២៥ រាជធានី-ខេត្ត ត្រូវអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**

**ជា សុផារ៉ា**

**ចម្លងជូន ÷**

- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ
  "ដើម្បីជ្រាប"
- មន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្ត ពាក់ព័ន្ធ
  "ដើម្បីអនុវត្ត"